វាយឡើងវិញជាភាសាខ្មែរពីឯកសារផ្លូវការ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

លេខ: ១៦៣ ប្រក/ ថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ ២០០២

**ប្រកាសស្តីពីការរៀបចំលេខាធិការដ្ឋាន នៃគណៈកម្មការសុរិយោដីក្រុងប៉ៃលិន និងសមាសភាពគណៈកម្មការសុរិយោដីខណ្ឌក្នុងក្រុងប៉ៃលិន**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកត/១១៨៩/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ១៩៩៩ ប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រម លេខនស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសអោយប្រើច្បាប់ភូមិបាល
- បានឃើញអនុក្រឹត្យលេខ ៤៧ អនក្រ/បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ ២០០២ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃគណៈកម្មការ សុរិយោដី
- បានឃើញអនុក្រឹត្យលេខ ៣៤៧ អនក្រ.តត.ចុះថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០០២ ស្តីពីការតែងតាំងសមាសភាពគណៈកម្មការសុរិយោដីថ្នាក់ជាតិ
- យោងប្រកាសអន្តរក្រសួងលេខ០៧៧ ប្រកចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០០២ ស្តីពីការតែងតាំងសមាសភាពគណៈកម្មការសុរិយោដីថ្នាក់ខេត្ត-ក្រុង
- តាមសំណើរបស់គណៈកម្មការសុរិយោដីក្រុងប៉ៃលិន

**សំរេច**

ប្រការ ១ :

ត្រូវបានបង្កើតលេខាធិការដ្ឋាននៃគណៈកម្មការសុរិយោដីក្រុងប៉ៃលិន ដែលមានសមាសភាពដូចខាងក្រោម :

| | | |
|---|---|---|
| ១- លោក តាន់ តែម | អនុប្រធានមន្ទីរ ដនសស.ក្រុងប៉ៃលិន | ជាប្រធាន |
| ២- លោក សូ សុខុន | អនុប្រធានមន្ទីរ ដនសស.ក្រុងប៉ៃលិន | ជាអនុប្រធាន |
| ៣- លោក ហ៊ុល សារឿន | អនុប្រធានការិយាល័យសុរិយោដីនិងភូមិសាស្រ្តនៃមន្ទីរដនសស.ក្រុងប៉ៃលិន | ជាមន្ត្រីជំនួយការ |
| ៤- លោក នួន ប៊ុនថុល | មន្ត្រីការិយាល័យសុរិយោដី និងភូមិសាស្រ្តនៃមន្ទីរដនសសក្រុងប៉ៃលិន | ជាមន្ត្រីជំនួយការ |

Downloaded from http://www.khmerlaws.com

ប្រការ ២ :

ត្រូវបានរៀបចំសមាសភាពគណៈកម្មការសុរិយោដីខណ្ឌក្នុងក្រុងប៉ៃលិនដូចខាងក្រោម :

ក. គណៈកម្មការសុរិយោដីខណ្ឌប៉ៃលិន :

| | | |
|---|---|---|
| ១- លោក សោភ័ណ្ឌ បញ្ញា | ប្រធានការិយាល័យ ដនសភ. ខណ្ឌប៉ៃលិន | ជាប្រធាន |
| ២- លោក អ៊ុំ សារ៉ន | មន្ត្រីការិយាល័យ ដនសភ ខណ្ឌប៉ៃលិន | ជាសមាជិក |
| ៣- លោក អ៊ូច សារ៉ែម | មន្ត្រីការិយាល័យ ដនសភ ខណ្ឌប៉ៃលិន | ជាសមាជិក |

ខ. គណៈកម្មការសុរិយោដីខណ្ឌសាលាក្រៅ :

| | | |
|---|---|---|
| ១- លោក គង់ ផល្លា | ប្រធានការិយាល័យ ដនសភខណ្ឌសាលាក្រៅ | ជាប្រធាន |
| ២-លោក មាស សារី | អនុប្រធានការិយាល័យ ដនសភខណ្ឌសាលាក្រៅ | ជាសមាជិក |
| ៣- លោក ទុយ វណ្ណា | មន្ត្រីការិយាល័យ ដនសភ. | ជាសមាជិក |

ប្រការ ៣ :

លេខាធិការដ្ឋាននៃគណៈកម្មការសុរិយោដីក្រុង គណៈកម្មការសុរិយោដីខណ្ឌទាំងអស់ក្នុងក្រុងប៉ៃលិន មានបេសកកម្មអនុវត្តនូវកិច្ចរបស់ខ្លួនដូចមានចែងក្នុងអនុក្រឹត្យ លេខ ៤៧ អនក្រ.បក ចុះថ្ងៃទី ៣១ ខែឧសភា ឆ្នាំ ២០០២ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី ។

ប្រការ ៤:

នាយកខុទ្ទកាល័យ ប្រធានលេខាធិការដ្ឋាននៃគណៈកម្មការសុរិយោដីថ្នាក់ជាតិ ប្រធានគណៈកម្មការសុរិយោដីក្រុងប៉ៃលិន ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីក្រុងប៉ៃលិន អស់លោកដូចមានរាយនាមក្នុងប្រការ ១ និងប្រការ២ ត្រូវអនុវត្តប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

Downloaded from http://www.khmerlaws.com